ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៧៧៦១ សជណ.កសក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទទួលពាក្យបណ្តឹងតាមរយៈគេហទំព័ររបស់អគ្គាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានកិត្តិយសសូមជូនដំណឹងដល់គ្រប់អង្គភាព មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មន្ត្រីរាជការទូទៅក្រោមឱវាទក្រសួង និងសាធារណជនទាំងអស់មេត្តាជ្រាបថា អគ្គាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងដាក់ឱ្យដំណើរការជាផ្លូវការ នូវប្រព័ន្ធទទួលពាក្យបណ្តឹងតាមរយៈគេហទំព័ររបស់អគ្គាធិការដ្ឋាន(GI.MAFF.GOV.KH) គ្រប់ពេលវេលាចាប់ពីពេលនេះតទៅ ដើម្បីទទួលពាក្យបណ្តឹងញត្តិតវ៉ា ឬបណ្តឹងបរិហារទាំងឡាយរបស់បណ្តាអង្គភាព មន្ត្រីរាជការទូទៅក្រោមឱវាទក្រសួង និងសាធារណជនដែលទទួលនូវបញ្ហាបាតុភាពនានា ឬភាពមិនប្រក្រតីជាយថាហេតុ ដែលកើតមានឡើងពាក់ព័ន្ធនឹងការងារដឹកនាំគ្រប់គ្រងរបស់អង្គភាពនានាក្រោមឱវាទក្រសួង។

ទទួលបានសេចក្តីជូនដំណឹងនេះ ខ្ញុំសង្ឃឹមថាគ្រប់អង្គភាព មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មន្ត្រីរាជការទូទៅក្រោមឱវាទក្រសួង និងសាធារណជនទាំងអស់មេត្តាចូលរួមសហការអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ស្វាគមន៍

ថ្ងៃ ៣ ៩ ១៥ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០២០
រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

**ចម្លងជូន៖**
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
  " ដើម្បីជ្រាបជាព័ត៌មាន "
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ:(០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ:(៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chomkarmon Phnom penh, Cambodia. Phone:(023) 726 128/726 129 Fax:(855) 23-217 320